# តើអ្នកត្រូវការ តេស្ត PCR ជំងឺ COVID-19 នៅពេលណា?

ការធ្វើតេស្តជំងឺ COVID-19 គឺមានជាទូទៅ នៅក្នុងរដ្ឋម៉ាស្សាជូសេត្ត។ រកកន្លែងធ្វើតេស្តមួយ នៅជិតអ្នក ឬទស្សនា អំពីការធ្វើតេស្ត COVID-19 ដើម្បីស្វែងយល់ អំពីប្រភេទធ្វើតេស្ត ជំងឺ  COVID-19 ខុសៗគ្នា ឬធ្វើតេស្តនៅពេលណា និងត្រូវធ្វើអ្វីខ្លះ បើសិនអ្នកធ្វើតេស្ត មានលទ្ធផលវិជ្ជមាន។

មានការធ្វើតេស្តជំងឺ COVID-19 ពីរប្រភេទ ដែលមានជាទូទៅ សំរាប់សាធារណៈ៖ តេស្តអង្គអតិសុខុមប្រាណរហ័ស ដែលមានជាប្រដាប់ ធ្វើតេស្តនៅផ្ទះ និងអាចនឹងធ្វើបានដោយខ្លួនឯង និងតេស្ត PCR ដែលជាតេស្តត្រូវបានធ្វើ នៅតាមវេជ្ជមន្ទីរ ដូចជានៅកន្លែង ធ្វើតេស្តបញ្ឈប់ការឆ្លងរាលដាល របស់រដ្ឋ Commonwealth។

DPH ឲ្យឱវាទថា តេស្តអង្គអតិសុខុមប្រាណរហ័ស គឺជារបៀបម្យ៉ាងអាចទទួលយកបាន ទៅនឹងការធ្វើតេស្ត PCR នៅក្នុងស្ថានការណ៍ភាគច្រើន រួមទាំងក្នុងស្ថានការណ៍ខាងក្រោម៖

- ដើម្បីចេញពីការនៅដាក់ឡែក ឬការឃុំខ្លួន ស្របតាមឧបទេស DPH
- ដើម្បីទទួលវិធីព្យាបាល ដូចជាថ្នាំ អង្គបដិបក្ខប្រាណ ម៉ូណូក្លូណាល់ ឬថ្នាំប្រឆាំងវីរុស បើសិនអ្នកជំងឺ ឋិតក្នុងហានិភ័យខ្ពស់ សំរាប់មានជំងឺធ្ងន់ធ្ងរ

## តេស្ត COVID-19 អង្គអតិសុខុមប្រាណរហ័ស៖

តេស្តអង្គអតិសុខុមប្រាណរហ័ស (ដូចជា ប្រដាប់ធ្វើតេស្តនៅផ្ទះ) អាចប្រើបានយ៉ាងងាយស្រួល និងបានលទ្ធផលលឿនក្នុង  15 នាទី។

### ឲ្យបានប្រដាប់មួយនៅទីណា៖

- នៅលើធ្នើរ តាមឱសថស្ថានក្នុងតំបន់ ដូចជា CVS ឬ Walgreens
- ហាងលក់រាយផ្សេងៗទៀត ដូចជា Amazon ឬ Walmart
- វាក៏អាចបានចែកចាយ តាមរយៈ និយោជក កម្មវិធីតាមក្រុង សាលារៀនមណ្ឌល និងដៃគូរសហគមន៍ ផ្សេងៗទៀត។
- បញ្ជាយកប្រដាប់ធ្វើតេស្ត តាមប្រៃសណីយ៍ មកពីរដ្ឋាភិបាលសហព័ន្ធ៖
  - អភិបាលកិច្ច លោក Biden មានប្រដាប់ធ្វើតេស្ត COVID-19 រហ័សនៅផ្ទះ សំរាប់អ្នកស្រុកទាំងអស់ តាមរយៈទំរង់បញ្ជាយកថ្មី តាមគេហទំព័រ។
  - ក្រុមគ្រួសារនិមួយៗ មានសិទ្ធិទទួលប្រដាប់ធ្វើតេស្ត ដល់ទៅ 4 តាមរយៈកម្មវិធីនេះ។
  - ប្រដាប់ធ្វើតេស្តអង្គអតិសុខុមប្រាណរហ័សនៅផ្ទះ អាចបញ្ជាយកមកពី ការិយាល័យប្រៃសណីយ៍សហរដ្ឋ នៅ តេស្ត COVID នៅផ្ទះ | USPS។




### ការធានារ៉ាប់រងសុខភាព សំរាប់តេស្តអង្គអតិសុខុមប្រាណរហ័ស

- តេស្តអង្គអតិសុខុមប្រាណរហ័ស (នៅផ្ទះ) ឥឡូវនេះគឺបានរ៉ាប់រង ដោយក្រុមហ៊ុនធានារ៉ាប់រង ដូចបានតម្រូវដោយ រដ្ឋាភិបាលសហព័ន្ធ។ សំរាប់ព័ត៌មានថែមទៀត ស្តីពីការរ៉ាប់រងនោះ សូមទស្សនា របៀបទទួល ប្រដាប់ធ្វើតេស្ត COVID-19 គ្មានវេជ្ជបញ្ជា នៅផ្ទះរបស់អ្នក ឥតគិតថ្លៃ | CMS.gov។
- ក្រុមហ៊ុនធានារ៉ាប់រងសុខភាព នឹងរ៉ាប់រងប្រដាប់ធ្វើតេស្តនៅផ្ទះទាំងនេះ គ្មានវេជ្ជបញ្ជាចំនួន 8 សំរាប់បុគ្គលម្នាក់ ក្នុងមួយខែ។ សមាជិក MassHealth គឺបានបញ្ចូលក្នុងនោះ។
- អ្នកស្រុកគួរតែសាកសួរ ក្រុមហ៊ុនធានារ៉ាប់រងរបស់គេ សំរាប់ព័ត៌មាន អំពីរបៀបគំរោងរបស់គេ នឹងរ៉ាប់រងប្រដាប់ធ្វើតេស្ត គ្មានវេជ្ជបញ្ជា និងទីកន្លែងដើម្បីទិញប្រដាប់ធ្វើតេស្ត តាមរយៈឱសថស្ថានពេញចិត្ត និងហាងលក់រាយ ត្បិតសេចក្តីពិស្តារ អាចនឹងខុសៗគ្នា។ អ្នកស្រុកក៏គួរតែសាកសួរ អ្នកផ្តល់ការធានារ៉ាប់រងរបស់គេដែរ មុននឹងទិញប្រដាប់ធ្វើតេស្ត តាមរយៈហាងលក់រាយ តាមអនឡាញ ដូចជា Amazon ត្បិតតម្លៃពេញ អាចនឹងមិនបានរ៉ាប់រងទេ។

**តេស្ត PCR គឺមាននៅរាប់រយកន្លែង ពាសពេញរដ្ឋ Commonwealth រួមទាំង 40 កន្លែងធ្វើតេស្ត "បញ្ឈប់ការឆ្លងរាលដាល" រដ្ឋបានឧបត្ថម្ភដោយឥតគិតថ្លៃ សំរាប់អ្នកស្រុករដ្ឋម៉ាស្សាជូសេត្ត។ សំរាប់បញ្ជីពេញលេញ នៃកន្លែងធ្វើតេស្ត ទស្សនា www.mass.gov/gettested**